Australian Government
Department of Human Services

KHMER

# Child Care Subsidy

ប្រាក់ជំនួយថែទាំកុមារដែលគេហៅថា Child Care Subsidy ជួយដល់ការចំណាយលើការថែទាំកុមារដែលបានការអនុញ្ញាតពីរដ្ឋ។ ប្រសិនបើលោកអ្នកមានសិទ្ធិទទួលប្រាក់ជំនួយនេះ យើងនឹងបង់ប្រាក់នេះទៅឲ្យមណ្ឌលថែទាំកុមារដោយផ្ទាល់ដើម្បីបញ្ចុះប្រាក់ចំណាយដែលលោកអ្នកត្រូវបង់។

ដើម្បីអាចបានទទួលប្រាក់ជំនួយនេះ លោកអ្នកត្រូវ៖

- ថែទាំកុមារអាយុ១៣ឆ្នាំ ឬក៏ក្មេងជាងនេះ ដែលមិនទាន់ចូលសាលារៀនមធ្យមសិក្សា លុះត្រាណាមានការលើកលែង
- ប្រើប្រាស់សេវាកម្មថែទាំកុមារដែលបានការអនុញ្ញាតពីរដ្ឋ
- ទទួលខុសត្រូវចំពោះការបង់ប្រាក់ថ្លៃឈ្នួលថែទាំកុមារ ហើយនិង
- ធ្វើទៅតាមតម្រូវការនៃការបានសិទ្ធិរស់នៅ និងតម្រូវការចាក់ថ្នាំវ៉ាក់សាំងការពារ។

ដើម្បីធ្វើទៅតាមតម្រូវការនៃការបានសិទ្ធិរស់នៅ លោកអ្នក និងដៃគូរបស់លោកអ្នកត្រូវតែរស់នៅក្នុងប្រទេសអូស្ត្រាលី ហើយត្រូវមាន៖

- សញ្ជាតិអូស្ត្រាលី ឬក៏កាន់ទិដ្ឋាការរស់នៅអចិន្ត្រៃយ៍
- កាន់ Special Category (ទិដ្ឋាការពិសេស) ឬក៏
- កាន់ទិដ្ឋាការរស់នៅបណ្ដោះអាសន្នជាក់លាក់ណាមួយ ដូចជា Partner Provisional (ទិដ្ឋាការដៃគូបណ្ដោះអាសន្ន) ឬ Temporary Protection (ទិដ្ឋាការបានការការពារបណ្ដោះអាសន្ន)។

លោកអ្នកអាចបំពេញទៅតាមតម្រូវការមានសិទ្ធិរស់នៅប្រសិនបើ៖

- លោកអ្នក ឬដៃគូរបស់លោកអ្នកជានិស្សិតពីបរទេស ដែលបានការធានាពីរដ្ឋាភិបាលអូស្ត្រាលីឲ្យមកសិក្សានៅក្នុងប្រទេសអូស្ត្រាលី ឬក៏
- លោកអ្នកជួបប្រទះនឹងការលំបាក ឬក៏ស្ថិតក្នុងកាលៈទេសៈពិសេស។

លោកអ្នកអាចបានការលើកលែងពីលក្ខណៈវិនិច្ឆ័យខ្លះនៅក្នុងកាលៈទេសៈជាក់លាក់ណាមួយ។

ចំនួននៃប្រាក់ជំនួយ Child Care Subsidy ដែលលោកអ្នកមានសិទ្ធិទទួលបាននឹងអាស្រ័យទៅលើ៖

- ប្រាក់ចំណូលរបស់ក្រុមគ្រួសារលោកអ្នក
- អត្រាប្រាក់ម៉ោងអតិបរមា (hourly rate cap) ដែលផ្អែកលើប្រភេទនៃការថែទាំកុមារដែលបានការអនុញ្ញាតដែលលោកអ្នកប្រើ និងអាយុកូនរបស់លោកអ្នក ហើយនិង
- ចំនួនម៉ោងដែលលោកអ្នក និងដៃគូចំណាយធ្វើសកម្មភាព ដែលបានការទទួលស្គាល់ពីរដ្ឋ។

## ប្រាក់ចំណូលក្រុមគ្រួសារ

យើងនឹងប្រើការប៉ាន់ប្រមាណប្រាក់ចំណូលរបស់ក្រុមគ្រួសារលោកអ្នក ដើម្បីគណនាភាគរយនៃប្រាក់កម្រៃម៉ោង ដែលយើងនឹងជួយឧបត្ថម្ភ។

humanservices.gov.au

## កម្រៃប្រាក់ម៉ោងអតិបរមា

ចំនួននៃប្រាក់ជំនួយថែទាំកុមារ Child Care Subsidy ដែលលោកអ្នកមានសិទ្ធិទទួលបាននឹងអាស្រ័យទៅលើប្រភេទនៃការថែទាំកុមារដែលលោកអ្នកប្រើដែលបានការអនុញ្ញាតពីរដ្ឋ និងអាយុកូនរបស់លោកអ្នក។ ភាគរយនៃ Child Care Subsidy នឹងអនុវត្តទៅលើប្រាក់កម្រៃម៉ោងដែលលោកអ្នកត្រូវបង់ទៅឲ្យកន្លែងថែទាំកុមារ ឬក៏កម្រៃប្រាក់ម៉ោងអតិបរមា - គឺយកជម្រើសណាដែលតិចជាងគេ។

## ការធ្វើតេស្តសកម្មភាពកិច្ចការ

ចំនួនម៉ោងដែលលោកអ្នកអាចទទួលប្រាក់ជំនួយថែទាំកុមារ គឺអាស្រ័យទៅ លើចំនួនម៉ោងនៃសកម្មភាពកិច្ចការដែលលោកអ្នកធ្វើប្រចាំ២សប្តាហ៍ដែលបានការទទួលស្គាល់ពីរដ្ឋ។

### សកម្មភាពនានាដែលបានការទទួលស្គាល់រួមមាន៖

- ធ្វើការបានប្រាក់កម្រៃ - រួមទាំងការឈប់សម្រាកដែលបានប្រាក់ខែ ដូចជាការឈប់សម្រាកសម្រាលកូន
- ការសិក្សារៀនសូត្រ ឬក៏ការហ្វឹកហ្វឺនការងារ
- ការងារមិនបានប្រាក់កម្រៃនៅក្នុងពាណិជ្ជកម្មគ្រួសារ
- កំពុងស្វែងរកការងារ
- ធ្វើការងារស្ម័គ្រចិត្ត
- ធ្វើមុខរបរកចំណូលខ្លួនឯង ហើយនិង
- សកម្មភាពដទៃទៀត ដែលគេពិនិត្យមើលតាមករណីនីមួយៗ។

គេនឹងមានការលើកលែងខ្លះសម្រាប់មាតាបិតាដែលមិនអាចធ្វើទៅតាមតម្រូវការនៃការធ្វើតេស្តសកម្មភាពការងារ ដែលមានមូលហេតុសមរម្យ ក៏ដូចជាការជួយទំនុកបម្រុងដល់កុមារដែលចូលរួមនៅក្នុងមត្តេយ្យសាលា។

### ចំនួនម៉ោងនៃសកម្មភាព

ប្រសិនបើលោកអ្នកមានដៃគូ យើងនឹងពិនិត្យមើលលើកម្រិតនៃសកម្មភាពកិច្ចការរបស់អ្នកទាំងពីរ។ យើងនឹងគណនាចំនួនម៉ោងសម្រាប់ប្រាក់ជំនួយថែទាំកុមារ Child Care Subsidy ដែលលោកអ្នកអាចទទួលបានរាល់ពេល២សប្តាហ៍ ដោយប្រើកម្រិតសកម្មភាពកិច្ចការណាដែលតិចជាងគេក្នុងចំណោមអ្នកទាំងពីរ។

## ការដកយកប្រាក់ទុកសិន

ដើម្បីជួយកាត់បន្ថយបញ្ហាបង់ប្រាក់ឲ្យលើសកម្រិត យើងនឹងដកប្រាក់ទុក៥ 5% ពីប្រាក់ជំនួយថែទាំកុមារ Child Care Subsidy របស់លោកអ្នកសម្រាប់រាល់ពេល២សប្តាហ៍។

នៅរាល់ចុងឆ្នាំសារពើពន្ធយើងនឹងទូទាត់ប្រាក់ជំនួយរបស់លោកអ្នកឲ្យត្រូវចំនួន។ យើងនឹងទូទាត់ប្រាក់ជំនួយនេះដោយធ្វើការប្រៀបធៀបប្រាក់ចំណូលពីប៉ាន់ប្រមាណ និងប្រាក់ចំណូលពិតប្រាកដ។ ការធ្វើដូច្នេះគឺដើម្បីធានាឲ្យបានថា លោកអ្នកនឹងទទួលបានប្រាក់ជំនួយត្រឹមត្រូវគ្រប់ចំនួន។

ប្រសិនបើលោកអ្នកប៉ាន់ប្រមាណប្រាក់ចំណូលទាប លោកអ្នកអាចនឹងទទួលបានប្រាក់ជំនួយថែទាំកុមារលើសកម្រិត ធ្វើឲ្យលោកអ្នកត្រូវបង់សងប្រាក់វិញនៅថ្ងៃមុខ។ យើងនឹងប្រើប្រាក់ជំនួយ Child Care Subsidy ដែលយើងបានដកទុកសិន ដើម្បីបញ្ចុះចំនួនប្រាក់ដែលលោកអ្នកត្រូវបង់សងវិញ។

ប្រសិនបើលោកអ្នកប៉ាន់ប្រមាណប្រាក់ចំណូលគ្រួសារខ្ពស់ ហើយលោកអ្នកមិនបានទទួលប្រាក់ជំនួយថែទាំកុមារ Child Care Subsidy គ្រប់គ្រាន់ យើងខ្ញុំនឹងបង់សងទៅលោកអ្នកវិញដោយផ្ទាល់នូវចំនួនដែលខ្វះខាត។ ប្រាក់ទាំងនេះនឹងរួមទាំងប្រាក់ជំនួយ Child Care Subsidy ដែលយើងបានដកទុកសិន។

លោកអ្នកអាចមានលទ្ធភាពផ្លាស់ប្តូរចំនួនប្រាក់ដែលគេដកទុកសិន។

## របៀបដាក់ពាក្យសុំប្រាក់ជំនួយថែទាំកុមារ Child Care Subsidy

ដើម្បីធ្វើការដាក់ពាក្យសុំតាមអ៊ីនធើរណិត លោកអ្នកត្រូវការគណនី myGov និងគណនីអ៊ីនធើរណិតរបស់ Centrelink។ គណនី myGov របស់លោកអ្នកត្រូវតែភ្ជាប់ជាមួយនឹងគណនីនៅក្នុង Centrelink។

ប្រើគណនី Centrelink តាមអ៊ីនធើរណិតរបស់លោកអ្នកតាមរយៈ myGov ដើម្បីផ្តល់ព័ត៌មានរបស់លោកអ្នក និងឯកសារនានាសម្រាប់ជួយដល់ការដាក់ពាក្យ។

## Additional Child Care Subsidy

ប្រាក់ជំនួយថែទាំកុមារបន្ថែមទៀតដែលគេហៅថា Additional Child Care Subsidy ផ្តល់ជំនួយបន្ថែមដល់ក្រុមគ្រួសារសម្រាប់ជួយដល់ប្រាក់ឈ្នួលថែទាំកុមារ។ លោកអ្នកត្រូវមានសិទ្ធិទទួលបានប្រាក់ជំនួយ Child Care Subsidy ដើម្បីអាចទទួលបានប្រាក់ជំនួយ Additional Child Care Subsidy បន្ថែម។ មានប្រាក់ជំនួយថែទាំកុមារបន្ថែមចំនួន៣ប្រភេទ ដែលលោកអ្នកអាចដាក់ពាក្យសុំបាន៖

- Additional Child Care Subsidy (Grandparent) ជាប្រាក់ជំនួយបន្ថែម ដែលជួយសម្រួលដល់ការថែទាំកុមារ ប្រសិនបើលោកអ្នកជាជីដូន/ជីតា ឬជាជីទួត ដែលមានមុខងារបឋមជាអ្នកថែទាំចៅ ឬចៅទួត។ លោកអ្នកត្រូវតែទទួលបានប្រាក់ឧបត្ថម្ភប្រាក់ចំណូល។
- Additional Child Care Subsidy (Temporary Financial Hardship) ជាប្រាក់ជំនួយបន្ថែម ដែលជួយសម្រួលដល់ការថែទាំកុមារសម្រាប់រយៈពេលខ្លី ប្រសិនបើលោកអ្នកកំពុងជួបប្រទះនឹងបញ្ហាលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ដោយសារតែស្ថានភាពកាលៈទេសៈលើសពីការគ្រប់គ្រងរបស់លោកអ្នក។
- Additional Child Care Subsidy (Transition to Work) ជាប្រាក់ជំនួយបន្ថែម ដែលជួយសម្រួលដល់ការថែទាំកុមារ ប្រសិនបើលោកអ្នកកំពុងប្តូរស្ថានភាពពីការកំពុងទទួលបានប្រាក់ឧបត្ថម្ភប្រាក់ចំណូលទៅចូលរួមការងារ, ការសិក្សា ឬសកម្មភាពហ្វឹកហ្វឺន។

## របៀបដាក់ពាក្យសុំប្រាក់ជំនួយថែទាំកុមារបន្ថែម Additional Child Care Subsidy

ដើម្បីធ្វើការដាក់ពាក្យសុំតាមអ៊ីនធើរណិត លោកអ្នកត្រូវការគណនី myGov និងគណនីអ៊ីនធើរណិតរបស់ Centrelink។ គណនី myGov របស់លោកអ្នកត្រូវតែភ្ជាប់ជាមួយនឹងគណនីនៅក្នុង Centrelink។

ប្រើគណនី Centrelink តាមអ៊ីនធើរណិតរបស់លោកអ្នកតាមរយៈ myGov ដើម្បីផ្តល់ព័ត៌មានរបស់លោកអ្នក និងឯកសារនានាសម្រាប់ជួយដល់ការដាក់ពាក្យ។

## ការប៉ាន់ប្រមាណប្រាក់ជំនួយថែទាំកុមារ

លោកអ្នកអាចប្រើ Payment and Service Finder ជាភាសាអង់គ្លេសដើម្បីធ្វើការវាយតម្លៃប៉ាន់ប្រមាណលើចំនួនប្រាក់ដែលលោកអ្នកមានសិទ្ធិទទួលបានសម្រាប់ជំនួយថែទាំកុមារ។ សូមចូលទៅវ៉ិបសាយថ៍ **humanservices.gov.au/paymentfinder**

## ចំពោះព័ត៌មានបន្ថែម

- ចូលទៅវ៉ិបសាយថ៍ **humanservices.gov.au/childcaresubsidy** ដើម្បីបានទទួលព័ត៌មានបន្ថែមជាភាសាអង់គ្លេស
- ចូលទៅវ៉ិបសាយថ៍ **humanservices.gov.au/yourlanguage** ជាទីដែលលោកអ្នកអាចអាន, ស្ដាប់ ឬក៏ទស្សនាព័ត៌មានជាភាសារបស់លោកអ្នក
- ទូរសព្ទទៅលេខ **131 202** ដើម្បីនិយាយជាមួយយើងខ្ញុំជាភាសារបស់លោកអ្នកអំពីសេវាកម្ម និងប្រាក់ជំនួយនានារបស់ Centrelink។
- ទូរសព្ទទៅសេវាកម្មបកប្រែភាសា Translating and Interpreting Service (TIS National) តាមលេខ **131 450** ដើម្បីនិយាយជាមួយយើងខ្ញុំជាភាសារបស់លោកអ្នកអំពីប្រាក់ជំនួយ និងសេវាកម្មនានារបស់ Medicare និងអំពី Child Support។
- អញ្ជើញទៅមជ្ឈមណ្ឌលផ្ដល់សេវាកម្មរបស់យើងដោយផ្ទាល់។

**កំណត់សម្គាល់៖** ការហៅចេញពីលេខទូរសព្ទតាមផ្ទះរបស់លោកអ្នកទៅកាន់លេខទូរសព្ទដែលចាប់ផ្ដើមដោយលេខ ‘13’ ពីគ្រប់ទីកន្លែងនៅក្នុងប្រទេសអូស្ត្រាលី គឺត្រូវអស់ប្រាក់ក្នុងអត្រាតម្លៃមួយថេរ។ អត្រាថេរនោះអាចខុសគ្នាពីតម្លៃនៃទូរសព្ទក្នុងតំបន់ ហើយក៏អាចខុសគ្នារវាងក្រុមហ៊ុនផ្ដល់សេវាកម្មទូរសព្ទផងដែរ។ ការហៅទៅលេខ ‘1800’ ចេញពីលេខទូរសព្ទតាមផ្ទះរបស់លោកអ្នក គឺមិនគិតថ្លៃទេ។ ការហៅទូរសព្ទពីលេខទូរសព្ទសាធារណៈ និងពីទូរសព្ទដៃអាចត្រូវគេគិតថ្លៃខ្ពស់ជាងនេះ ឬទៅតាមរយៈពេលនៃការនិយាយ។

## សេចក្ដីប្រកាសមិនទទួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះគឺក្នុងគោលបំណងគ្រាន់តែជាការណែនាំផ្ដល់ព័ត៌មានអំពីប្រាក់ជំនួយ និងសេវាកម្មប៉ុណ្ណោះ។ វាជាការទទួលខុសត្រូវរបស់លោកអ្នកក្នុងការសម្រេចចិត្តដាក់ពាក្យសុំប្រាក់ជំនួយ ហើយនិងការដាក់ពាក្យទាក់ទងនឹងកាលៈទេសៈជាក់លាក់របស់លោកអ្នក។

# Child Care Subsidy

Child Care Subsidy helps with the cost of approved child care. If you are eligible, we'll pay it directly to your child care provider to reduce the fees you pay.

To be eligible you must:

- care for a child 13 years of age or younger who is not in secondary school, unless an exemption applies
- use an approved child care service
- be responsible for paying the child care fees, and
- meet residency and immunisation requirements.

To meet the residency requirements, you or your partner must be living in Australia and either:

- be an Australian citizen or hold a permanent residence visa
- hold a Special Category visa, or
- hold a certain temporary visa type, for example, a Partner Provisional or Temporary Protection visa.

You may also meet the residency requirements if:

- you or your partner are a student from overseas, sponsored by the Australian Government to study in Australia, or
- you are in hardship or special circumstances apply.

You may be exempt from some of these criteria in specific circumstances.

The amount of Child Care Subsidy you're entitled to will depend on:

- your family's income
- the hourly rate cap based on the type of approved child care you use and the age of your child, and
- the hours of recognised activities you and your partner do.

## Family income

We will use your family income estimate to work out the percentage of your hourly fee we will subsidise.

## Hourly rate cap

The amount of Child Care Subsidy you are entitled to will depend on the type of approved child care you use and the age of your child. Your Child Care Subsidy percentage will apply to either the hourly fee you are charged by your child care service or the hourly rate cap, whichever is lower.

## Activity test

The number of hours of subsided child care you can get is based on the number of hours of recognised activities you do each fortnight.

**Recognised activities:**

- paid work – including leave, such as maternity leave
- study and training
- unpaid work in family business
- looking for work
- volunteering
- self-employment, and
- other activities on a case-by-case basis.

There will be exemptions for parents who legitimately cannot meet the activity test requirements, as well as to support children's participation in preschool.

### Hours of activity

If you have a partner we will look at both of your activity levels. We will work out how many hours of Child Care Subsidy you can get each fortnight by using the lower of the two activity levels.

## Withholding

To help reduce the likelihood of an overpayment, we will withhold 5% of your Child Care Subsidy each fortnight.

At the end of each financial year we'll balance your payments. We will do this by comparing your income estimate to your actual income. This will ensure you have received the correct amount of subsidy.

If you underestimate your income you may have an overpayment which you'll need to pay back. We will use the Child Care Subsidy we withheld to reduce the amount you have to pay back.

If you overestimate your family income and don't receive enough Child Care Subsidy, we'll pay any outstanding amount directly to you. This will include the Child Care Subsidy we withheld.

You are able to vary your withholding amount.

## How to claim Child Care Subsidy

To make a claim online you need a myGov account and a Centrelink online account. Your myGov account must be linked to Centrelink.

Use your Centrelink online account through myGov to provide your information and any supporting documents.

## Additional Child Care Subsidy

Additional Child Care Subsidy offers some families extra help with their child care fees. You must be eligible for Child Care Subsidy to be eligible for Additional Child Care Subsidy. There are 3 different types you can apply for:

- Additional Child Care Subsidy (Grandparent), which helps with the cost of child care if you are a grandparent or great grandparent with primary care of your grandchild or great grandchild. You must receive an income support payment.
- Additional Child Care Subsidy (Temporary Financial Hardship), which gives short-term help with the cost of child care if you are experiencing temporary financial hardship due to circumstances beyond your control.
- Additional Child Care Subsidy (Transition to Work), which helps with the cost of child care if you are transitioning from an income support payment by engaging in work, study or training activities.

## How to apply for Additional Child Care Subsidy

To apply online you need a myGov account and a Centrelink online account. Your myGov account must be linked to Centrelink.

Use your Centrelink online account through myGov to provide your information and any supporting documents.

## Estimate your child care fee assistance

You can use the Payment and Service Finder in English to see how much child care fee assistance you may be entitled to. Go to **humanservices.gov.au/paymentfinder**

## For more information

- go to **humanservices.gov.au/childcaresubsidy** for more information in English
- go to **humanservices.gov.au/yourlanguage** where you can read, listen to or watch information in your language
- call **131 202** to speak with us in your language about Centrelink payments and services
- call the Translating and Interpreting Service (TIS National) on **131 450** to speak with us in your language about Medicare and Child Support payments and services
- visit a service centre.

**Note**: calls from your home phone to '13' numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to '1800' numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It’s your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.